# សម្មោទមានជាតក

ដោយ សឹម ចាន់ឌី(Chandy Soem)

កែសម្រួលដោយយន់ សុធា

ថ្ងៃទី២៤ ខែកុម្ភៈ ២៥៥៤

*(ចូលរួមគំនិត) នៅក្នុងអត្ថន័យនៃជាតក(រឿងនិទាន)នេះ មានន័យក្នុងការពិចារណា ដល់អ្នក(មេ)គ្រប់គ្រង និងស្ថានភាពគ្រួសារ សីលធម៌ ការព្យាយាម ការដោះស្រាយបញ្ហា។ តើក្នុងរឿងនេះដូចសុភាសិតខ្មែរថាៈ៖ "ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិ ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណាប់បង្ហាញចោរ" ដែរឬទេ?)*

*កាលពីព្រេងនាយ ព្រះពោធិសត្វមួយអង្គបានចាប់កំណើតជាសត្វក្រួចនៅក្នុងព្រៃមួយ នាក្រុងពារាណសី ហើយមានសត្វក្រួចជាច្រើនពាន់ បាននៅក្រោមការដឹកនាំរបស់សត្វក្រួចជាព្រះពោធិសត្វ។ កាលនោះមានព្រានព្រៃម្នាក់តែងតែទៅរកទាក់សត្វក្រួចដោយបញ្ចេញសំឡេងអឺតបន្លំជាសត្វក្រួចដែលវង្វេងជាច់ហ្វូងហើយយំហៅរកគ្នា។នៅពេលដែលសត្វក្រួចហើរមកចុះជុំហើយ ព្រានព្រៃក៏ប្រញាប់បោះលប់ ដើម្បីសង្គ្រុបចាប់សត្វក្រួចទាំងហ្វូងនោះដាក់ទ្រុង រួចយកទៅលក់ឯផ្សា ព្រោះនេះជារបរចិញ្ចឹមជីវិតរបស់គាត់។ ថ្ងៃមួយព្រះពោធិសត្វដែលជាមេហ្វូង បានដឹងហេតុការណ៍នៃមហន្តរាយនេះក៏ពិចារណាថាៈ អំពើរបស់ព្រានព្រៃនេះ ថ្ងៃណាមួយប្រាកដជាធ្វើឲ្យហ្វូងសត្វក្រួចទាំងអស់វិនាសផុតពូជជាមិនខាត។បន្ទាប់មកមេក្រួចបានកោះហៅ ពួកក្រួចទាំងអស់ ឲ្យមកចូលរួមប្រជុំ ដើម្បីរកវិធានការដោះស្រាយពីបញ្ហាគ្រោះថ្នាក់នេះ។ក្រោយពីការពិភាក្សាគ្នាមកសត្វក្រួចដែលជាព្រះពោធិសត្វបានសម្រេចចិត្តថាៈ ចូរអ្នកទាំងឡាយធ្វើតាមបណ្តាំយើងដូចតទៅនេះ "ពីពេលនេះតទៅ បើមានព្រានព្រៃបោះលប់មកលើក្រុមយើងយ៉ាងកាលណា ចូរយើងម្នាក់ៗត្រូវតាំងស្មារតីឲ្យបានរឹងប៊ឹងកុំតក់ស្លុតឲសោះ យើងត្រូវបញ្ចេញក្បាលតាមចន្លោះលប់រួចយើងទាំងអស់គ្នាខំប្រឹងទទះស្លាបហើរឲ្យខ្លាំង។ ធ្វើយ៉ាងនេះយើងអាចសួយនាំលប់យកទៅលើអាកាស រួចយើងនឹងនាំលប់នោះទៅជម្រុះចោលក្នុងគម្ពោជព្រៃណាមួយដែលមានស្លឹកក្រាស់ ហើយពួកយើងក៏អាចគេចពីលប់នោះបាន។ បើយើងធ្វើដូច្នេះ ឲ្យបានស្រុះៗ*

គ្នានោះ យើងប្រាកដជារំដោះខ្លួន រួចពីកម្លាំងដៃនៃព្រានដូចបំណងជាមិនខាន។ សត្វក្រួចទាំងអស់ ក៏សន្យាយល់ព្រមធ្វើតាមបញ្ជារបស់សត្វក្រួចមេហ្វូងដែលជាព្រះពោធិសត្វ ដោយប្រុងប្រយ័ត្នហើយតែងតែគេចរួចខ្លួនពីគ្រោះថ្នាក់ជាដរាបតរៀងទៅ។ នៅពេលដែលសត្វក្រួចទាំងអស់ស្ទុះហើរនាំលប់ទៅលើអាកាស នាយព្រានព្រៃខំរត់តាម យកលប់ពីក្នុងបន្លាក៏មិនបាន។ រៀងរាល់ថ្ងៃ ព្រានព្រៃតែងតែត្រឡប់មកផ្ទះវិញដោយដៃទទេ។

ចំណែកប្រពន្ធព្រានព្រៃ កាលឃើញប្តីត្រឡប់មកផ្ទះវិញដោយដៃទទេ គ្មានប្រាក់ដូចសព្វដង ក៏កើតក្តីម្ទូរម៉ៅ ក្តៅក្រហាយ ហើយចោទប្តីថា៖នែ! លោកប្តី! រាល់ថ្ងៃត្រឡប់មកផ្ទះវិញដៃទទេដូច្នេះ តើអ្នកអាល័យទៅជាប់ដៃរវល់ជាមួយស្រីថ្មីទេដឹង? ព្រានព្រៃក៏បានឆ្លើយថា៖ "ឱ! អូនសម្លាញ់ ឆ្អើយ បងគ្មានទៅមានស្រីឯណាទេ សូមកែវមាសមេជឿបងចុះ។ ការពិតគឺហ្វូងសត្វក្រួច ទាំងអស់នោះវាឆ្លាតណាស់ឥឡូវនេះពួកវាស្រុះស្រួលរស់នោះជាមួយគ្នាដូចក្បាលមួយអញ្ចឹង"។នៅពេលដែលបងបោះលប់គ្របប៉ាំព័ទ្ធលើពួកវាភ្លាម ពួកវាស្ទុះហើរដំណាលគ្នា ហើយហើរនាំលប់ឡើងយកទៅជាមួយ រួចទម្លាក់ចោលលើគម្ពោធព្រៃ ដែលមានសុទ្ធតែបន្លា។ ប៉ុន្តែសូមពៅព្រលឹងកុំព្រួយ ថ្ងៃណាមួយដែលពួកវាបែកបាក់សាមគ្គីគ្នា ហើយថ្ងៃនោះសូម្បីតែកូនក្រួចមួយ ក៏មិនអាចរួចពីកណ្តាប់ដៃបងបានដែរ ហើយអូននឹងញញឹមវិញជាមិនខាន។

ពោលដូច្នេះហើយ នាយព្រានព្រៃក៏ច្រៀងតិចៗ ដោយរីករាយថា: ៖

| | |
|---|---|
| ឲ្យតែពួកឯង | នៅខំប្រឹងប្រែង |
| ស្រុះស្រួលនឹងគ្នា | ឯងអាចគេចផុត |
| ពីក្តីមរណា | បើឯងឈ្លោះគ្នា |
| ជាថ្ងៃអង្សា | ថ្ងៃនោះហើយណា |
| ឯងជាប់លប់អញ | គ្មានរួចមួយឡើយ។ |

នៅពេលក្រោយមក មានសត្វក្រួចមួយកំពុងចឹកសំបុកកណ្តៀររកចំណី ស្រាប់តែរបូតជើងធ្លាក់មកក្រោមប៉ះក្បាលសត្វក្រួចមួយទៀត។ ពេលនោះ មានសំឡេងក្រួចនៅពីខាងក្រោម បានបន្លឺឡើងថា៖

*-អាណាជាន់ក្បាលអញហ្អា!*

*-សូមទោសលោក! ខ្ញុំគ្មានបំណងទេ គឺខ្ញុំរបូតជើងធ្លាក់ពីសំបុកកណ្តៀវ ដោយអចេតនាទេ សូមលោកមេត្តាកុំខឹងអី!*

*-មិនបានទេ! ឯងនេះព្រហើនណាស់ រញ៉ីរញ៉ៃបែបហ្នឹងឬ ដែលជាអ្នកមានកម្លាំងរើខ្លួនអោយរួចផុតពីលប់របស់ព្រានព្រៃនោះ? (ក្រួចទាំងពីរ ឆ្លើយតបទាំងកម្រោល)*

*ជម្លោះរវាងសត្វក្រួចទាំងពីរ ចេះតែរាលដាលបន្តទៅទៀត បណ្តាលអោយបរិយាកាសកាន់តែអាប់អួ ដោយមានក្រុមកាន់ជើងគ្នា ទាំងសងខាងកាន់តែច្រើនឡើងៗ។ ដោយពុំអាចសម្រុះសម្រួលបាន ក្រួចដែលជាពោធិសត្វ យល់ឃើញស្ថានភាពមិនស្រួលក៏នាំគ្នា មួយក្រុមហើរចេញពីទីនោះទៅ។ ស្ថិតនៅក្នុងភាពច្របូកច្របល់នោះ ស្រាប់តែលប់របស់នាយព្រានព្រៃធ្លាក់ព្រឹបលើសត្វក្រួច ទាំងពីរក្រុម ដែលកំពុងតែឈ្លោះគ្នានោះ។ ដោយការភិតភ័យតក់ស្លុត ស្រឡាំងកាំងក្នុងភាពអាសន្ននោះ សត្វក្រួចទាំងពីរក្រុមភ្លេចអស់បណ្តាំព្រះពោធិសត្វ ហើយក៏ស្រែកប្រចាំគ្នាថា៖*

*“ បើឯងពូកែណាស់ ឥឡូវម្តេចក៏មិនហើរនាំលប់នេះមុនអញទៅ?*

*ចុះឯងម៉េចក៏មិនស្ទុះមុនអញទៅ?*

*នៅពេលដែលសត្វក្រួចទាំងពីរក្រុម កំពុងតែឈ្លោះប្រកែកគ្នាដូច្នេះ ព្រានព្រៃក៏ក្រសោបលើកលប់ចាប់ក្រួចទាំងអស់នោះ បញ្ចូលក្នុងទ្រុងរួចត្រឡប់ទៅផ្ទះវិញ ដោយក្តីរីករាយ។ ថ្ងៃនេះ ភរិយារបស់ព្រានព្រៃបានញញឹមដូចបំណងរបស់គេមែន។*

*លុះព្រះអង្គបានសំដែងរឿងអតីតកាលរួច សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់បញ្ជាក់ថា៖ “ម្នាល់ភិក្ខុទាំងឡាយ ការឈ្លោះគ្នារវាងបងប្អូនឯង រមែងតែងតែនាំមកនូវសេចក្តីវិនាស។ សូម្បីតែសត្វក្រួចក៏ដោយ ក៏គេអាចយកជ័យជម្នះលើសត្រូវបាន អោយតែគេចេះសាមគ្គី (ត្រូវរ៉ូវគ្នា)។ ផ្ទុយទៅវិញ គេអាចធ្លាក់ក្នុងក្តីមហន្តរាយ បើកាលណាគេនៅតែឈ្លោះគ្នាហើយ ប្រកាន់អាកប្បកិរិយារឹងរូស យកឈ្នះយកចាញ់រវាងគ្នាងជាធំ”។*

ទ្រង់ប្រជុំជាតក សត្វក្រួចដែលពោរពេញទៅដោយកំហឹងក្តៅក្រហាយនោះ គឺជាតួអង្គនៃទេវទត្ត។ រីឯព្រះពោធិសត្វជាមេហ្វូងដឹកនាំនៃហ្វូងក្រួច ដែលមានប្រាជ្ញានោះ គឺតួអង្គតថាគតនេះឯង។

សូមអរគុណ